## សារលិខិត
## សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាស «ទិវាសន្តិភាពអន្តរជាតិ» ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤

**សូមថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ**
**បងប្អូនជនរួមជាតិជាទីស្នេហា!**

អង្គការសហប្រជាជាតិបានកំណត់យក **ថ្ងៃទី២១ ខែកញ្ញា** ជារៀងរាល់ឆ្នាំ ជាថ្ងៃដ៏សំខាន់សម្រាប់បណ្ដាប្រទេសនៅទូទាំងសកលលោកប្រារព្ធ **«ទិវាសន្តិភាពអន្តរជាតិ»** ដើម្បីបង្ហាញនូវការប្ដេជ្ញាចិត្តរួមគ្នាទប់ស្កាត់ និងបញ្ឈប់ជម្លោះប្រដាប់អាវុធ ព្រមទាំងលើកកម្ពស់គុណតម្លៃសន្តិភាព ក៏ដូចជាការរំលឹកដល់ការខិតខំប្រឹងប្រែងនានាក្នុងការរួមចំណែកធ្វើឱ្យសម្រេចបាននូវសន្តិភាពនៅលើសកលលោក។ នៅក្នុងឆ្នាំ២០២៤នេះ ទិវាសន្តិភាពអន្តរជាតិ ប្រព្រឹត្តទៅក្រោមមូលបទ «**ការបណ្ដុះវប្បធម៌សន្តិភាព**»ដែលឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃការបណ្ដុះស្មារតី និងវប្បធម៌សន្តិភាព ទៅកាន់សហគមន៍គ្រប់ជំនាន់ តាមរយៈយន្តការ អប់រំផ្លូវការ និងក្រៅផ្លូវការនានា នៅក្នុងប្រទេសនីមួយៗលើសកលលោក។

ក្នុងនាមជាប្រទេសដែលបានឆ្លងកាត់សង្គ្រាមជាច្រើនទសវត្សរ៍ កម្ពុជាទទួលស្គាល់នូវសារៈសំខាន់ដែលមិនអាចកាត់ថ្លៃបាននៃសន្តិភាព និងស្ថិរភាព ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការអភិវឌ្ឍរបស់ប្រទេសនីមួយៗ ក៏ដូចជាសហគមន៍អន្តរជាតិ។ បើគ្មានសន្តិភាពនិងស្ថិរភាពនោះទេ យើងក៏ពុំអាចសម្រេចនូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពបានដែរ។

តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំព្រះករុណា ខ្ញុំ សូមសម្ដែងនូវអំណរសាទរ និងចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងការប្រារព្ធ «**ទិវាសន្តិភាពអន្តរជាតិ**» ដ៏មហោឡារិកនេះ ដើម្បីលើកកម្ពស់ការយល់ដឹងពីតម្លៃនៃសន្តិភាពដែលមិនអាចកាត់ថ្លៃបាន និងសូមបញ្ជាក់ឡើងវិញនូវឆន្ទៈដ៏មោះមុតរបស់ប្រជាពលរដ្ឋកម្ពុជា ក្នុងការការពារនិងចូលរួមកសាងសន្តិភាព ស្ថិរភាព នៅក្នុងប្រទេស តំបន់ និងសកលលោកឱ្យបានគង់វង្សស្ថិតស្ថេរ ស្របតាមការលើកឡើងរបស់ **ឯកឧត្ដម អាន់តូនីញ៉ូ ហ្គូតេរ៉េស** អគ្គលេខាធិការអង្គការសហប្រជាជាតិថា «នៅក្នុងពិភពលោកមួយដែលជាប់គាំងដោយជម្លោះ វិសមភាព និងការរើសអើង យើងត្រូវតែខិតខំបន្ថែមទៀតដើម្បីលើកកម្ពស់ការសន្ទនា ការយោគយល់គ្នាទៅវិញទៅមក និងសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា»។

**ជនរួមជាតិជាទីស្នេហា!**

ពលិកម្មប្រកបដោយស្មារតីស្នេហាជាតិរបស់យុទ្ធជន យុទ្ធនារី និងប្រជាពលរដ្ឋនៅគ្រប់ដំណាក់កាលនៃប្រវត្តិសាស្ត្រ បាននាំឱ្យកម្ពុជាសម្រេចបាននូវការអភិវឌ្ឍជឿនលឿនដូចសព្វថ្ងៃនេះ។ នៅក្រោមព្រះរាជបូជនីយកិច្ចដឹកនាំដ៏ឈ្លៀវឈ្លាសរបស់ព្រះមហាវីរក្សត្រខ្មែរ **ព្រះករុណា ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ប្រជាជាតិយើងទទួលបានឯករាជ្យទាំងស្រុងពីអាណានិគមបារាំង នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

គួរឱ្យសោកស្ដាយ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះបានផ្ដល់ឱ្យប្រជាជាតិយើងស្គាល់សុខសន្តិភាពត្រឹមរយៈពេលខ្លីប៉ុណ្ណោះ។ អស់រយៈពេលជាងពីរទសវត្សរ៍ យើងបានឆ្លងកាត់ភ្នក់ភ្លើងសង្គ្រាម អំពើប្រល័យពូជសាសន៍ សោកនាដកម្ម ការបែកបាក់រងទុក្ខវេទនាខ្លោចផ្សារកទីបំផុតគ្មាន ដែលបានធ្វើឱ្យយើងទាំងអស់គ្នាយល់ច្បាស់ពីតម្លៃនៃសន្តិភាព និងស្ថិរភាព ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រទេសជាតិ។

ជាភ័ព្វសំណាង អតីតកាលដ៏លំបាកវេទនារបស់ប្រជាជាតិយើង ត្រូវបានបញ្ចប់ទាំងស្រុងនៅឆ្នាំ១៩៩៨ បន្ទាប់ពីការអនុវត្តដោយជោគជ័យនូវ **«នយោបាយឈ្នះ-ឈ្នះ»** របស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបាននាំមកវិញ នូវសុខសន្តិភាព ស្ថិរភាព ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុងជូនប្រជាជាតិយើង។

ក្នុងរយៈពេលជាងពីរទសវត្សរ៍ ចុងក្រោយនេះ កម្ពុជាសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនលើគ្រប់វិស័យ ជាពិសេសការសម្រេច និងរក្សាបាននូវចីរភាពនៃសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយវិបុលភាពសម្រាប់ប្រជាជនទូទាំងប្រទេស។ ជាតថភាព កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យមជាង ៧% ក្នុងមួយឆ្នាំ នៅមុនដំណាក់កាលនៃវិបត្តិជំងឺកូវីដ១៩ និងបានប្រែក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥ និងកំពុងត្រៀមចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ព្រមទាំងបាននិងកំពុងបោះជំហានឆ្ពោះទៅមុខដើម្បីក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ជាមួយគ្នានេះ កម្ពុជាដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមរាំងជល់ និងពឹងផ្អែកលើជំនួយបរទេស បច្ចុប្បន្នកម្ពុជាអាចឈរបានដោយខ្លួនឯង និងស្មើមុខស្មើមាត់លើឆាកអន្តរជាតិ ព្រមទាំងពង្រីកមហិច្ឆតាលើកស្ទួយមោទនភាពជាតិឱ្យខ្ពស់រុងរឿងដូចពីអតីតកាល។ ក្នុងបុព្វហេតុនេះ កាលពីថ្ងៃទី៥ ខែសីហា កន្លងទៅ កម្ពុជាបានបើកការដ្ឋានសាងសង់**ព្រែកជីកហ្វូណនតេជោ** ដោយមានការឯកភាពជាតិពីគ្រប់មជ្ឈដ្ឋានទាំងក្នុងនិងក្រៅប្រទេសប្រកបដោយមោទនភាព ដែលគម្រោងជាប្រវត្តិសាស្ត្រនេះ នឹងផ្ដល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសកម្ពុជា ជាពិសេសលើវិស័យដឹកជញ្ជូន ការវិនិយោគ បង្កើតតំបន់ពាណិជ្ជកម្ម មជ្ឈមណ្ឌលកស្ដុភារកម្ម ការអភិវឌ្ឍផែរណប ការពង្រីកតំបន់អភិវឌ្ឍន៍កសិកម្ម ជាពសាស្ត្រ វារីវប្បកម្ម និងទេសចរណ៍ជាដើម ដើម្បីបន្សល់ទុកជាសមិទ្ធផលជាប្រវត្តិសាស្ត្រសម្រាប់កូនចៅខ្មែរគ្រប់ជំនាន់។

ទន្ទឹមនេះ ដើម្បីធានានូវសុខសន្តិភាព រាជរដ្ឋាភិបាលបានបន្តគិតគូយ៉ាងម៉ត់ចត់អំពីសុខមាលភាពរបស់ប្រជាជន ក្នុងនោះ របបសន្តិសុខសង្គមត្រូវបានបម្រើកាន់តែទូលំទូលាយសម្រាប់ប្រជាពលរដ្ឋកម្ពុជាក្នុងការធានាបាននូវសង្គតិភាព សមធម៌និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋ រួមចំណែកកាត់បន្ថយភាពក្រីក្រ និងអស្ថិរភាពសង្គម។

បន្ថែមពីនេះ ក្នុងបុព្វហេតុទប់ស្កាត់ជម្លោះប្រដាប់អាវុធនិងសង្គ្រាមនៅក្នុងពិភពលោក កម្ពុជាបាន និងកំពុងចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការថែរក្សាសន្តិភាពពិភពលោក ក្រោមឆត្ររបស់អង្គការសហប្រជាជាតិ។ ចាប់ពីឆ្នាំ២០០៦ មកដល់បច្ចុប្បន្ននេះ កម្ពុជាបានបញ្ជូនកងកម្លាំងរក្សាសន្តិភាព សរុបចំនួន ៩.៨១៩នាក់ ក្នុងនោះ ស្ត្រី ៨៥៦នាក់ ទៅបំពេញបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហ-ប្រជាជាតិក្នុងប្រទេសចំនួន ១០ រួមមាន ប្រទេសឆាដ, ស៊ូដង់, ស៊ូដង់ខាងត្បូង, អាហ្វ្រិកកណ្ដាល, លីបង់, ស៊ីប, ស៊ីរី, ម៉ាលី, យេម៉ែន និងកុងហ្គោ។ បច្ចុប្បន្ននេះ កងកម្លាំងរក្សាសន្តិភាពរបស់កម្ពុជាសរុប ចំនួន ៦២៧ នាក់ (ក្នុងនោះស្ត្រី ១៣១នាក់) កំពុងបំពេញបេសកកម្មថែរក្សាសន្តិភាពនៅប្រទេសស៊ូដង់, ស៊ូដង់ខាងត្បូង, លីបង់, អាហ្វ្រិកកណ្ដាល, យេម៉ែន និងកុងហ្គោ។ នេះ គឺជាមោទនភាពដ៏ធំធេងបំផុតសម្រាប់ប្រទេសកម្ពុជា នៅលើឆាកអន្តរជាតិ។

**ជនរួមជាតិជាទីស្នេហា!**

រាជរដ្ឋាភិបាលនៅគ្រប់នីតិកាលទាំងអស់ បានយកចិត្តទុកយ៉ាងខ្ជាប់ខ្ជួនក្នុងការលើកកម្ពស់វប្បធម៌សន្តិភាព ដោយទទួលស្គាល់ថាសង្គមមាន សន្តិភាព ស្ថិរភាព និងសុខដុមរមនា គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញថា បើគ្មានសន្តិភាពទេ នោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការលុបបំបាត់ភាពក្រីក្រ ការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ការផ្ដល់ការអប់រំប្រកបដោយគុណភាព សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ក៏ពុំអាចសម្រេចបានដែរ។

ទន្ទឹមនេះ ដើម្បីបណ្ដុះវប្បធម៌សន្តិភាព រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងដាក់ចេញនូវគោលនយោបាយ និងយន្តការនានាដើម្បីទទួលយក និងដោះស្រាយរាល់សំណូមពរនានាពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដែលនៅក្នុងនោះរាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តយ៉ាងសកម្មឱ្យមានការចូលរួមពីគ្រប់គណបក្សនយោបាយទាំងអស់ នៅក្នុងដំណើរការរបស់រាជរដ្ឋាភិបាលដើម្បីធានាថាសំឡេងប្រជាពលរដ្ឋពីគ្រប់ទីកន្លែងត្រូវបានគិតគូរ និងឆ្លើយតបដោយមិនប្រកាន់បែងចែកនិន្នាការនយោបាយឡើយ។

ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវប្រជាពលរដ្ឋកម្ពុជាគ្រប់មជ្ឈដ្ឋាន ចូលរួមជាមួយរាជរដ្ឋាភិបាលធ្វើការប្រឆាំងដាច់ខាតចំពោះចេតនាបង្កភាពចលាចលក្នុងសង្គមតាមរយៈការប្រឌិតព័ត៌មានមិនពិត ការភូតភរកែ្លងបន្លំ និងការញុះញង់បងប្អូនប្រជាពលរដ្ឋឱ្យធ្វើសកម្មភាពដែលបង្កអសន្តិសុខ បំផ្លាញសន្តិភាព និងស្ថិរភាពសង្គមដែលអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការបណ្ដុះវប្បធម៌សន្តិភាព និងការរក្សាបានចីរភាពនៃការអភិវឌ្ឍសង្គមជាតិយើង។ ផ្ទុយពីរាជរដ្ឋាភិបាល ក្រុមប្រឆាំងជ្រុលនិយមមួយចំនួន បានប្រឌិតព័ត៌មានមិនពិតគ្មានមូលដ្ឋានពិតប្រាកដ ញុះញង់បងប្អូនប្រជាពលរដ្ឋយើង ឱ្យធ្វើសកម្មភាពដែលបង្កអសន្តិសុខ បំផ្លាញសន្តិភាព ធ្វើឱ្យប៉ះពាល់ដល់ការបណ្ដុះវប្បធម៌សន្តិភាព និងសន្តិសុខរបស់ប្រទេស។

**ជនរួមជាតិជាទីស្នេហា!**

សន្តិភាពងាយណាស់ក្នុងការបាត់បង់ តែពិបាកក្នុងការស្វែងរកមកវិញ ហើយបើរកមកបានវិញ ក៏ត្រូវការពេលវេលា និងការលះបង់ជាច្រើនផង។ ហេតុនេះហើយ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា សូមបញ្ជាក់សាជាថ្មីឡើងវិញ នូវការប្ដេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាលក្នុងការថែរក្សា «**សន្តិភាព**» និងការតម្កល់ «**សន្តិភាព**» ជាគុណតម្លៃខ្ពស់បំផុត គឺគ្មានការប្រែប្រួលជាដាច់ខាត ទោះបីក្នុងតម្លៃណាក៏ដោយ។

ខ្ញុំព្រះករុណា ខ្ញុំ មានជំនឿយ៉ាងមុតមាំថា ពិធីអបអរសាទរ «**ទិវាសន្តិភាពអន្តរជាតិ**» ឆ្នាំនេះនឹងបង្ហាញឱ្យឃើញកាន់តែច្បាស់អំពីឆន្ទៈនិងការប្ដេជ្ញាចិត្តកាន់តែក្លៀវក្លារបស់រាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋកម្ពុជាទាំងអស់ក្នុងការខិតខំការពារសន្តិភាព ការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ការសន្ទនា ការដោះស្រាយជម្លោះដោយសន្តិវិធី និងការយោគយល់គ្នាទៅវិញទៅមក សំដៅកសាងពិភពលោកមួយប្រកបដោយសន្តិសហវិជ្ជមាន ភាពធន់ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

ជាកិច្ចបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយព្រះពរ និងប្រសិទ្ធពរជូនដល់ជនរួមជាតិជាទីស្នេហា សូមចៀសផុតពីជំងឺឆ្លងនានា និងសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃ ពុធ ១ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០២៤

**ហ៊ុន ម៉ាណែត**